# ជំពូកទី ៩
# ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

Draft

# ជំពូកទី ៩
# ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

## ៩.១ សេចក្តីផ្តើម

បច្ចុប្បន្ននេះ ដីសម្បទានត្រូវបានរីកចម្រើនកាន់តែច្រើនឡើងនៅក្នុងប្រទេសកម្ពុជា ដែលបណ្តាលមកពីការកែទម្រង់គោលនយោបាយនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ជាមួយនឹងការលើកកម្ពស់លើការតម្រង់ទិសសេដ្ឋកិច្ចការដឹកនាំ និងទីផ្សារមូលដ្ឋាននៃសេដ្ឋកិច្ច (TOUCH SIPHAT, 2009)។ ការស្នើសុំដីសម្បទានសេដ្ឋកិច្ច ត្រូវបានគេវាយតម្លៃបានថា វាអាចជួយលើកកម្ពស់ដល់ជីវភាពរស់នៅរបស់ប្រជាជន ការពារបរិស្ថាន និងធនធានធម្មជាតិធ្វើការគ្រប់គ្រង ឬជៀសវាង ឬបង្រួមជាអប្បបរមានៃផលប៉ះពាល់ផ្នែកសង្គម ដោយជួយឲ្យមានការកើនឡើងនូវការងារជាដើម (OHCHR, 2007)។ រដ្ឋាភិបាលកម្ពុជាជឿជាក់ថា វាគឺជាវិធីដ៏ល្អមួយ ដើម្បីបង្កើនផលិតកម្មកសិកម្ម និងជាឱកាសការងារសម្រាប់ប្រជាជននៅក្នុងតំបន់ ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលនៅក្នុងការជំរុញដល់ការរីកលូតលាស់សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ទោះជាយ៉ាងណា នៅក្នុងការអនុវត្តក្រុមហ៊ុនឯកជនជាច្រើនបានយកដីធ្លីរបស់ប្រជាពលរដ្ឋក្នុងតំបន់ និងបានបំផ្លាញព្រៃធម្មជាតិ ដែលជាប្រភពមុខរបរដ៏សំខាន់នៅក្នុងការចិញ្ចឹមជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ (TOUCH SIPHAT, 2009)។

Draft

ជំពូកនេះ ផ្តោតជាសំខាន់ទៅលើការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន ដោយធ្វើការប្រៀបធៀបជាមួយនឹងការចូលរួមចំណែករបស់គម្រោងអភិវឌ្ឍន៍ ទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថាន។ គោលបំណងចម្បងក្នុងការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន គឺដើម្បីបង្ហាញឲ្យច្បាស់នូវផលចំណេញ ឬខាតបង់ក្នុងកម្រិតណាមួយដល់បរិស្ថាន និងសង្គម បើធៀបនឹងហេតុប៉ះពាល់អវិជ្ជមានដោយគម្រោង។ ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថានមានសារៈសំខាន់ក្នុងការចង្អុលបង្ហាញដល់សាធារណៈជន ពិសេសប្រមុខរដ្ឋាភិបាលដែលជាអ្នកមានសិទ្ធសម្រេចក្នុងគម្រោងផ្សេងៗ ឲ្យបានដឹងថា តើគម្រោងអភិវឌ្ឍន៍អាចផ្តល់ជាផលចំណេញ ឬការខាតបង់ដល់តម្លៃសេដ្ឋកិច្ច កម្រិតណាដល់សង្គមជាតិ។ ជាទូទៅ ការវិភាគសេដ្ឋកិច្ច ត្រូវបានធ្វើឡើងមុនពេលអនុញ្ញាតឲ្យអនុវត្តគម្រោងស្នើសុំ ដើម្បីធ្វើការប៉ាន់ស្មានពីផលចំណេញ និងថ្លៃចំណាយ ដែលជាទូទៅត្រូវបានធ្វើឡើង ដោយការប្រើប្រាស់តាមតម្លៃលើទីផ្សារ។ ដូច្នេះផលចំណេញ និងតម្លៃខាតបង់លើធនធានបរិស្ថាន និងសង្គម ដែលពុំមានតម្លៃនៅលើទីផ្សារ តែងតែត្រូវបានគេមើលរំលង ឬមិនត្រូវបានគេគិតគួរឲ្យបានគ្រប់ជ្រុងជ្រោយ នៅក្នុងការវិភាគសេដ្ឋកិច្ចនោះទេ។

គម្រោងវិនិយោគសម្រាប់ការអភិវឌ្ឍដំណាំអំពៅ និងអាកាស្យា របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល់ ខមភេនី លីមីតធីត ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាត ឲ្យធ្វើការដាំដុះ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឆ្នាំ ២០១១ (លិខិតលេខ ៩៩ សប្រទ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ និងបានចុះហត្ថលេខាលើកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១១)។

យើងបានធ្វើការសិក្សាបន្ថែម អំពីតម្លៃសេដ្ឋកិច្ចដែលត្រូវបាត់បង់ ដោយសារផលប៉ះពាល់បរិស្ថាន និងសង្គម ដោយភាពអវិជ្ជមាននៃសកម្មភាពគម្រោង។ លទ្ធផលនៅក្នុងជំពូកទី៧បង្ហាញថា ផលប៉ះពាល់អវិជ្ជមានសំខាន់បំផុតនៃគម្រោងកំពុងសិក្សានេះ គឺការបាត់បង់ធនធានព្រៃឈើ និងផលប្រយោជន៍ទាំងផ្ទាល់ និងប្រយោលដែលមនុស្សទទួលបានពីសេវាកម្មមុខងារប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។ នៅក្នុងជំពូកនេះយើងលើកយកមកបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃជាសាច់ប្រាក់ នៃផលប្រយោជន៍ព្រៃឈើដែលបាត់បង់ ដោយសារការប្រែក្លាយផ្ទៃដីព្រៃទៅជាផ្ទៃដីកសិកម្មក្នុងកិច្ចដំណើរការគម្រោងវិនិយោគនេះ។ នៅផ្នែកខាងក្រោមនៃជំពូកនេះ យើងនឹងធ្វើការលើកមកបង្ហាញនូវលទ្ធផលសង្ខេបនៃការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន (របាយការណ៍ចំណេញ ខាត)។

## ៩.២ តម្លៃសេដ្ឋកិច្ចនៃគម្រោង

### ៩.២.១ ភាពជឿជាក់នៃគម្រោង

ស្របទៅតាមការរំពឹងទុក ក៏ដូចជាការវិភាគទុកមុននៃគម្រោងវិនិយោគរបស់ក្រុមហ៊ុនបានឲ្យដឹងថា តាមរយៈការគណនាលំហូរសាច់ប្រាក់សុទ្ធ (Net Cash Flow) តម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value) តម្លៃបច្ចុប្បន្ន (Present Value) នៃលំហូរសាច់ប្រាក់រយៈពេល ២០ឆ្នាំដោយអត្រាការប្រាក់ ១០%ដែលបានបង្ហាញថាៈ

- តម្លៃបច្ចុប្បន្ន (Present Value) ក្រុមហ៊ុនត្រូវការដើមទុនប្រមាណជា ១០,៣លានដុល្លារអាមេរិក (១០.៣៥៥.៦២០ ដុល្លារអាមេរិក) ដើម្បីជាដើមទុនក្នុងរយៈពេល ៥ឆ្នាំដំបូងក្នុងអត្រាការប្រាក់១០%។
- តម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value) មានចំនួន ១៤.៦៦០.៩០០ដុល្លារអាមេរិក តម្លៃបច្ចុប្បន្នសុទ្ធនៃគម្រោងនេះជាចំនួនវិជ្ជមានដែលអាចសន្និដ្ឋានបានថា ការធ្វើអាជីវកម្មមានដំណើរការល្អ នឹងទទួលយកបាន។
- ការគណនា អត្រាវិនិយោគខាងក្នុង Internal Rate of Return (IRR) មានតម្លៃប្រមាណជា ១៨% តួលេខនេះធ្វើឲ្យក្រុមហ៊ុនអាចមានសង្ឃឹមក្នុងការធ្វើអាជីវកម្មរបស់ខ្លួន ព្រោះអត្រា Discount Rate កំនត់ត្រឹម ១០% តូចជាង Internal Rate of Return (IRR) ដែលមានរហូតដល់ ១៨%។
- រយៈពេលប្រមូលទុនមកវិញ (Payback Period) នៅក្នុងរង្វង់រយៈពេល ១១ឆ្នាំទៅ ១២ឆ្នាំ ក្រុមហ៊ុនអាចមានលទ្ធភាពទូទាត់សង និងប្រមូលបានមកវិញនូវដើមទុនវិនិយោគនៃគម្រោងអាជីវកម្មនេះ។
- សន្ទស្សន៍ផលចំណេញ (Profitability Index or Benefit/Cost Ratio) ក្នុងរយៈ ២០ ឆ្នាំដំបូងនេះត្រូវបានគណនាឃើញប្រហែលជា ១.៤៩។ គម្រោងវិនិយោគនេះអាចទទួលយកបាន ព្រោះសន្ទស្សន៍ផលចំនេញមានចំនួនច្រើនជាងមួយ ឬអាចនិយាយបានថា ១ដុល្លារដែលបានវិនិយោគ អាចនឹងត្រូវបានបង្កើនតម្លៃបាន ០.៤៩ដុល្លារអាមេរិក។

### ៩.២.២ តម្លៃសេដ្ឋកិច្ច

#### ៩.២.២.១ ទុនសម្រាប់ការវិនិយោគ

ដើម្បីដំណើរការការងារវិនិយោគនៅក្នុងគម្រោងនេះ ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អិនធើណេសិនណល ខមភេនី លីមីតធីត ត្រូវការដើមទុនប្រមាណជា ២៦.៤០២.២៣០ដុល្លារអាមេរិកសម្រាប់ការចំណាយលើការងារដាំដុះដំបូង ការសាងសង់សំណង់ស៊ីវិល ការចំណាយលើការទិញមធ្យោបាយផលិតកម្ម ការចំណាយលើប្រតិបត្តិការអាជីវកម្មក្នុងដំណាក់កាលដែលមានរយៈពេល ១០ឆ្នាំដំបូងនៃការអភិវឌ្ឍទៅលើការដាំដុះនេះ។ ទុនវិនិយោគត្រូវបានបែងចែកតាមខ្ទង់ចំណាយដូចខាងក្រោម។

តារាង ៩.១៖ ទុនវិនិយោគលម្អិតតាមវិស័យ

| ទុនសម្រាប់គម្រោងវិនិយោគ | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|
| -ទុនសម្រាប់ការងារដាំដុះដំបូង | ៦.០០៤.៣៥០ |
| -ទុនសម្រាប់សំណង់ស៊ីវិល | ១.៣៣០.០០០ |
| -ទុនសម្រាប់ការកសាងរោងចក្រកែច្នៃ | ៦.០០០.០០០ |
| -ទុនសម្រាប់គ្រឿងចក្រ | ២.៧៨០.០០ |
| -ទុនសម្រាប់ចំណាយលើសម្ភារៈការិយាល័យ | ៤១.៣០០ |
| -ទុនសម្រាប់ការចំណាយប្រតិបត្តិការអាជីវកម្ម | ១០.២៤៦.៥៨០ |
| *សរុប* | *២៦.៤០២.២៣០* |

Draft

ប្រភព៖ ផែនការមេរបស់ក្រុមហ៊ុន,២០១២

### ៩.២.២.២ របាយការណ៍ចំណូល និង ចំណេញ-ខាត

#### ក. របាយការណ៍ចំណូល

#### ក.១ ផលិតផល និងចំណូលពីការដាំអំពៅ

ទិន្នផលសម្រាប់ដំណាំអំពៅត្រូវបានគេប៉ាន់ប្រមាណថាទទួលបានប្រហែលជា៥០-៦០តោន/ហិកតា។ តម្លៃនៃការលក់ស្ករអំពៅត្រូវបានគេប៉ាន់ប្រមាណថាទទួលបាន ៣៧៨ដុល្លារក្នុងមួយតោន ហើយតម្លៃនេះត្រូវបានប្រើប្រាស់នៅក្នុងការគណនា ពីចំណូលក្នុងផែនការអាជីវកម្មរបស់គម្រោងវិនិយោគនេះ។

ផលិតផលអំពៅត្រូវបានគេរំពឹងថានឹងទទួលបានចំនួន ១៩.៥០០ តោននៅក្នុងឆ្នាំទី០២ និងកើនឡើងជាបន្ទាប់នៅក្នុងឆ្នាំបន្ទាប់ អាស្រ័យលើទំហំផ្ទៃដីដាំដុះសរុប។ នៅក្នុងឆ្នាំទី០៣ ផលអំពៅត្រូវបានគេរំពឹងថានឹងមានកំណើនដល់ ៣៨.៧៥០តោន ផលនៅក្នុងឆ្នាំទី០៤ និងកើនដល់ ៨១.៦០០តោន ឆ្នាំទី០៥ កើនឡើងដល់ ១៧១.៩០០តោន។ នៅឆ្នាំទី ០៦ ដល់ឆ្នាំទី ១០ ផលិតផលអំពៅត្រូវបានគេប៉ាន់ប្រមាណថា វាមានការកើនឡើងដល់ ២៨៥.០០០តោនក្នុងមួយឆ្នាំ។

អត្រានៃការបំលែងពីផលិតផលអំពៅ ទៅជាស្ករអំពៅត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនប្រហែលជា ១០%។ ផលិតផលស្ករអំពៅនឹងអាចទទួលបានចំនួនប្រមាណជា ១.៩៥០តោន/ឆ្នាំនៅក្នុងឆ្នាំទី ០២ និងមានចំនួនកើនឡើងដល់ ៣.៨៧៥តោននៅក្នុងឆ្នាំទី០៥ ផលិតផលនេះអាចកើនឡើងរហូតដល់ ១៧.១៩០តោននៅក្នុងឆ្នាំទី០៥។ ចាប់ពីឆ្នាំទី០៦ ដល់ឆ្នាំទី១០ ផលិតផលស្ករអំពៅត្រូវបានគេប៉ាន់ប្រមាណថាទទួលបានចំនួនប្រមាណជា ២៨.៥០០តោនក្នុងមួយឆ្នាំ។

#### ក.២ ផលិតផល និងចំណូលពីការដាំអាកាស្យា

តាមរយៈការគណនាផលអាកាស្យាដែលនឹងទទួលបានបង្ហាញថា នៅក្នុងឆ្នាំទី០៦ផលឈើដែលទទួលបានរហូតដល់ ១.០៥០ម៉ែត្រគូប។ ហើយកំណើនផលនេះនឹងកើនឡើងជារៀងរាល់ឆ្នាំទៅតាមផ្ទៃដីដែលបានដាំដុះ។ នៅក្នុងឆ្នាំទី១០ ផលឈើនឹងកើនឡើងដល់ ៥.៩៥០ម៉ែត្រគូប ហើយចាប់ពីឆ្នាំទី១១ ដល់ឆ្នាំទី ២០ ផលអាកាស្យានឹងទទួលបានរហូតដល់ ៥.៩៥០ម៉ែត្រគូបក្នុងមួយឆ្នាំ។

តម្លៃលក់ផលិតផលឈើអាកាស្យាត្រូវបានគេប៉ាន់ប្រមាណថា នឹងទទួលបានប្រមាណជា ១៨០ដុល្លារអាមេរិកនៅក្នុងមួយម៉ែត្រគូប(ជាតម្លៃទាបបំផុតដែលអាចទទួលបាន) ដែលយកមកគិតនៅក្នុងការវិភាគនេះ។ ចំណូលដែលបានមកពីការលក់ឈើអាកាស្យានឹងទទួលបាននៅក្នុងឆ្នាំទី០៦ ប្រមាណជា ១៨៩.០០០ដុល្លារអាមេរិក និងបន្តកើនឡើងនៅក្នុងឆ្នាំបន្តបន្ទាប់ ចំណែកនៅក្នុងឆ្នាំទី០៩ ចំណូលនឹងកើនឡើងដល់ ៨៥៥.០០០ដុល្លារក្នុងមួយឆ្នាំ។ ចាប់ពីឆ្នាំទី១០រហូតដល់ឆ្នាំទី២០នឹងទទួលបានប្រមាណ ១០,៧៧លានដុល្លារក្នុងមួយឆ្នាំ។ តារាងខាងក្រោមបង្ហាញពីចំណូលសរុបដែលទទួលបានពីផលអំពៅ និងផលនៃឈើអាកាស្យា នៅក្នុងមួយឆ្នាំ។

តារាង ៩.២ ៖ ចំណូលសរុបទទួលបានពីផលអំពៅ និងផលឈើអាកាស្យា

| បណ្តាឆ្នាំ | ចំណូល(ដុល្លារអាមេរិក) | បណ្តាឆ្នាំ | ចំណូល(ដុល្លារអាមេរិក) |
|---|---|---|---|
| ចំណូលឆ្នាំទី-០១ | - | ចំណូលឆ្នាំទី-១១ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០២ | ៧៣៧.១០០ | ចំណូលឆ្នាំទី-១២ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០៣ | ១.៤៦៤.៧៥០ | ចំណូលឆ្នាំទី-១៣ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០៤ | ៣.០៨៤.៤៨០ | ចំណូលឆ្នាំទី-១៤ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០៥ | ៦.៤៩៧.៨២០ | ចំណូលឆ្នាំទី-១៥ | ១១.១៧៨.០០០ |



Draft

| | | | |
|---|---|---|---|
| ចំណូលឆ្នាំទី-០៦ | ១០.៩៦២.០០០ | ចំណូលឆ្នាំទី-១៦ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០៧ | ១០.៩៥៣.០០០ | ចំណូលឆ្នាំទី-១៧ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០៨ | ១១.១៧៨.០០០ | ចំណូលឆ្នាំទី-១៨ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-០៩ | ១១.១៧៨.០០០ | ចំណូលឆ្នាំទី-១៩ | ១១.១៧៨.០០០ |
| ចំណូលឆ្នាំទី-១០ | ១១.១៧៨.០០០ | ចំណូលឆ្នាំទី-២០ | ១១.១៧៨.០០០ |

ប្រភព: ផែនការមេរបស់ក្រុមហ៊ុន,២០១៥

### ខ. របាយការណ៍ចំណេញ-ខាត

របាយការណ៍ចំណេញ-ខាត ត្រូវបានគេប៉ាន់ប្រមាណនៅក្នុងការសិក្សាក្នុងផ្នែកការវិភាគសេដ្ឋកិច្ចនៃគម្រោង។ ទំហំនៃផ្ទៃដីដាំដុះនឹងមានការប្រែប្រួលពី ៤០៥ហិកតានៅក្នុងឆ្នាំទី០១ ហើយកើនឡើងរហូតដល់ ២.៣៨១ហិកតាក្នុងឆ្នាំទី០៥ដំបូង។

យោងតាមរបាយការណ៍ចំណូល និងចំណេញ-ខាតបានបង្ហាញថារបាយការណ៍ខាត(-)កើតមានឡើងចាប់ពីឆ្នាំទី០១ ដល់ឆ្នាំទី០៥។ ទឹកប្រាក់ ៩៣១.២៦៨ដុល្លារអាមេរិក គឺជាការខាតបង់នៅក្នុងឆ្នាំទី០១ ទឹកប្រាក់ចំនួន ៨៦៦.៧០៩ដុល្លារអាមេរិក ជាទឹកប្រាក់ខាតនៅក្នុងឆ្នាំទី០២ ចំណែកឯក្នុងឆ្នាំទី០៣ ទឹកប្រាក់ខាតមានចំនួន ១.៣៨៦.២៧៥ដុល្លារអាមេរិក។ តារាងខាងក្រោមបង្ហាញពីរបាយកាណ៍ចំណេញ-ក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំទី ០១ ដល់ឆ្នាំទី១៥។

តារាង ៩.៣ ៖ របាយកាណ៍ចំណេញ-ក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំទី០១ ដល់ឆ្នាំទី១៥

| ចំណេញ-ខាតតាមឆ្នាំ | ចំនួនទឹកប្រាក់(ដុល្លារ) | ចំណេញ-ខាតតាមឆ្នាំ | ចំនួនទឹកប្រាក់(ដុល្លារ) |
|---|---|---|---|
| របាយការណ៍ឆ្នាំទី-០១ | (-) ៩៣១.២៦៨ | របាយការណ៍ឆ្នាំទី-០៩ | ២.៧៦៨.១២៤ |
| របាយការណ៍ឆ្នាំទី-០២ | (-) ៨៦៦.៧០៩ | របាយការណ៍ឆ្នាំទី-១០ | ២.២៥៣.៨៧៣ |
| របាយការណ៍ឆ្នាំទី-០៣ | (-) ១.៣៨៦.២៧៥ | របាយការណ៍ឆ្នាំទី-១១ | ៣.០០៩.១៨៧ |
| របាយការណ៍ឆ្នាំទី-០៤ | (-) ២.០១០.៧៤៧ | របាយការណ៍ឆ្នាំទី-១២ | ៣.២២១.៤៣៧ |
| របាយការណ៍ឆ្នាំទី-០៥ | (-) ១.៣៤២.២០១ | របាយការណ៍ឆ្នាំទី-១៣ | ៣.១៥២.៦៨៧ |
| របាយការណ៍ឆ្នាំទី-០៦ | ៥.៧៦៣.៩៧៥ | របាយការណ៍ឆ្នាំទី-១៤ | ៣.១៥២.៦៨៧ |
| របាយការណ៍ឆ្នាំទី-០៧ | ៣.៥៣៥.៩៣៨ | របាយការណ៍ឆ្នាំទី-១៥ | ៣.១៥២.៦៨៧ |
| របាយការណ៍ឆ្នាំទី-០៨ | ៣.២៥៧.៨៥៣ | | |

Draft

ប្រាក់ចំណេញសុទ្ធ (Net Income/Profit) ត្រូវបានប៉ាន់ប្រមាណថានឹងទទួលបានចាប់ពីឆ្នាំទី០៦ ចំនួន ៥.៧៦៣.៩៧៥ដុល្លារអាមេរិក។ នៅក្នុងឆ្នាំទី០៧ ប្រាក់សុទ្ធចំណេញបានប្រមាណជា ៣.៥៣៥.៩៣៨ដុល្លារអាមេរិកនិងកើនឡើងដល់ ៣.១៥២.៦៨៧ដុល្លារអាមេរិកនៅក្នុងឆ្នាំទី ២០។

## ៩.៣ តម្លៃបរិស្ថានធម្មជាតិ

នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នៅតាមជនបទដែលភាគច្រើនជាកសិករប្រមាណជា ៨៥% នៃកម្លាំងពលកម្មសរុប។ បន្ថែមលើសពីនេះទៅទៀត នៅក្នុងសកម្មភាពកសិកម្ម មានកសិករជាច្រើនបានធ្វើការប្រមូលផលពីព្រៃឈើដើម្បីបន្ថែមទៅលើប្រាក់ចំណូលរបស់ពួកគេ។ ព្រៃឈើនេះ ភាគច្រើនត្រូវបានគេមើលឃើញថាជាប្រភពធនធានដ៏សម្បូរបែប ដែលមិនគ្រាន់តែវាផ្តល់នូវផលិតផលឈើតែប៉ុណ្ណោះទេ វាក៏បានផ្តល់មកនូវអនុផលព្រៃឈើ

ជាច្រើនប្រភេទមានដូចជា ផ្តៅនិងឫស្សី ជ័រ ទឹកឃ្មុំ រុក្ខជាតិ ឱសថ និងសាច់សត្វព្រៃ ជាពិសេសវាក៏បានផ្តល់នូវប្រយោជន៍ដ៏សំខាន់ផ្សេងទៀតដែលរាប់បញ្ចូលទាំងតម្លៃវប្បធម៌ និងការផ្តល់សេវាអេកូឡូស៊ី (ឧទាហរណ៍៖ ជាកន្លែងស្តុកទឹក និងការគ្រប់គ្រងទឹកជំនន់) (McKenney, 2002)។

សេវានៃមុខងារប្រព័ន្ធអេកូឡូស៊ី(Ecosystem Services) សំដៅដល់ប្រភេទនានានៃលក្ខខណ្ឌ និងដំណើរការដែលអេកូស៊ីស្ទែមធម្មជាតិនានា និងប្រភេទផ្សេងៗធ្វើឲ្យមានលំនឹង និងបំពេញតម្រូវការរបស់មនុស្សបាន (REDD, 2014)។ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស តម្លៃសេដ្ឋកិច្ច វប្បធ៌ម ប្រពៃណី និងបរិស្ថាននៃការរស់នៅ ជាផ្នែកមួយដែលរួមចំណែកនៅក្នុងអេកូស៊ីស្ទែមព្រៃឈើ។ នៅពេលបច្ចុប្បន្នអេកូស៊ីស្ទែមព្រៃឈើ កំពុងទទួលរងការគម្រាមគំហែងដោយសារតែកំណើននៃប្រជាសាស្រ្ត និងសេដ្ឋកិច្ចដែលជាចលករធ្វើឲ្យការថែរក្សាព្រៃឈើមានតម្លៃតិចជាងតម្លៃនៃការទាញយក (REDD, 2014)។ ទោះជាយ៉ាងណាក្តីតម្លៃដែលមើលឃើញនេះជាតម្លៃដែលមាននៅលើទីផ្សារប៉ុណ្ណោះ ប៉ុន្តែពួកគេមិនបានបញ្ចូលនូវតម្លៃដែលមិនអាចមើលឃើញនៅលើទីផ្សារឡើយចំពោះការគណនាពីផលប្រយោជន៍នៃអេកូស៊ីស្ទែមព្រៃឈើ។ តម្លៃសេដ្ឋកិច្ចនៃផលិតផលរបស់អេកូស៊ីស្ទែម ឬសេវាកម្មរបស់អេកូស៊ីស្ទែមមួយ វាអាចមានទាំងតម្លៃដែលអាចប្រើប្រាស់បានដោយផ្ទាល់ និងតម្លៃដែលមិនអាចប្រើប្រាស់បានដោយផ្ទាល់ផងដែរ (Roongtawanreongsri, Sawangchote, Bumrungsri, & Suksaroj, 2014)។

នៅក្នុងរបាយការណ៍នេះយើងផ្តោតសំខាន់លើការបាត់បង់ផលប្រយោជន៍ចម្បងៗចំនួន ៥គឺ៖ ផលឈើ អនុផលព្រៃឈើ សេវាកម្មអភិរក្សទឹក សេវាកម្មអភិរក្សដី (សេវាកម្មការពារទីជម្រាល) និងសេវាកម្មស្រូបកាបូន។ ផលប្រយោជន៍ទាំង ៣ខាងក្រោយ ជាផលប្រយោជន៍ដែលមនុស្សទទួលបានដោយប្រយោលពីព្រៃឈើ តាមរយៈការធ្វើនិយ័តកម្មរបស់ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។ ផលប្រយោជន៍ទាំងនេះ ត្រូវបាត់បង់នៅពេលដីព្រៃឈើត្រូវបានប្រែក្លាយទៅជាដីកសិកម្ម (Kasper K. Hansen. & Top, 2006)។

## ៩.៣.១ តម្លៃអវិជ្ជមាននៃគម្រោងលើបរិស្ថានធម្មជាតិ

ដើម្បីប៉ាន់ស្មានពីតម្លៃនៃផល និងអនុផលព្រៃឈើដែលបាត់បង់ យើងត្រូវពឹងផ្អែកលើវិធីសាស្រ្ត Benefit Transfer ឬ Value Transfer (Brander, 2013)។ វិធីសាស្រ្តត្រូវបានយកមកអនុវត្តនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសមួយចំនួនទៀត ហើយក៏ត្រូវបានបំផុសឲ្យប្រើប្រាស់ដោយកម្មវិធីបរិស្ថានពិភពលោក (UNEP) ដើម្បីបំពេញតម្រូវការព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្តលើគម្រោងស្នើសុំមួយ ដែលមានផលប៉ះពាល់បរិស្ថាន-សង្គមគួរឲ្យកត់សម្គាល់។ Value Transfer ជារួមត្រូវបានគេធ្វើឡើងជា ៤ជំហាន៖ (១) ពិពណ៌នាអំពីគម្រោង (គោលនយោបាយ) ដែលកំពុងសិក្សា (២) ជ្រើសរើសព័ត៌មានពីការសិក្សាផ្សេងទៀតដែលស្រដៀងគ្នា (៣) ផ្ទេរតម្លៃពីការសិក្សានោះមកគណនាតម្លៃពាក់ព័ន្ធនឹងគម្រោងដែរកំពុងសិក្សា (៤) រាយការណ៍ពីលទ្ធផល (Brander, 2013)។ នៅខាងក្រោមនេះ ជាលទ្ធផលនៃការសិក្សាកន្លងមកដែលស្រដៀងគ្នា និងលទ្ធផលនៃការប៉ាន់ស្មានតម្លៃនៃផលឈើដែលបានបាត់បង់ដោយសារគម្រោងកំពុងសិក្សា។

### ៩.៣.១.១ ការស្តុក និង ស្រូបកាបូន

តម្លៃរបស់កាបូនស្តុកត្រូវបានគេធ្វើឡើងសម្រាប់ការកំណត់ពីភាពខុសៗគ្នា ដោយផ្អែកទៅតាមប្រភេទគម្រប់ដី ដែលមាននៅក្នុងតំបន់។ សម្រាប់ប្រទេសកម្ពុជា នៅមិនទាន់មាននៅឡើយទេចំពោះការប៉ាន់ប្រមាណពីតម្លៃទាំងនេះ (Kapos et al., 2010)។ ការសិក្សាកន្លងរបស់ប្រទេសជិតខាងក្នុងតំបន់ដែលមានលក្ខណៈស្រដៀងគ្នា និងប្រទេសកម្ពុកជាត្រូវបានយកមកប្រើប្រាស់ជាគោលនៅក្នុងការសិក្សាពីសមត្ថភាពនៃការស្រូបនិងស្តុកកាបូននៅក្នុងការសិក្សានេះ។ ភាគច្រើននៃទិន្នន័យដែលយកមកប្រើប្រាស់នៅក្នុងការបង្ហាញពីជីវម៉ាស់នៃការបូនត្រូវបានគណនាចំពោះតែ ជីវម៉ាស់ដែលមាននៅខាងលើផ្ទៃដីប៉ុណ្ណោះ ចំណែកផ្នែកនៃខាងក្រោមដីមិនត្រូវបានគេយកមក



Draft

គណនាឡើយ។ ដោយឡែកការសិក្សារបស់ (Kapos et al., 2010) បានបញ្ជាក់លទ្ធផលនៃការសិក្សារបស់លោក ជាការសិក្សាដីម៉ាស់នៃកាបូនដោយបានដាក់បញ្ចូលនៅដីម៉ាស់ខាងក្រោមដីក្នុងជម្រៅ ១ម៉ែត្រ។ ដូចនេះហើយទើប ក្រុមការងារសម្រេចជ្រើសរើសយកលទ្ធផលរបស់លោក (Kapos et al., 2010) ដើម្បីជាមូលដ្ឋាននៅក្នុងការគណនាពីដីម៉ាសតាមប្រភេទព្រៃនីមួយៗ។

តារាង ៩.៤ ៖ តម្លៃនៃកាបូនស្តុក និងសេវាកម្មស្រូបកាបូនតាមប្រភេទព្រៃ

| ប្រភេទអេកូស៊ីស្ទែម | ជីវម៉ាស់កាបូនសរុប (តោន) | កំហាប់ $CO_2$ សមមូល (តោន) | តម្លៃសេវាកម្មស្តុកកាបូន (ដុល្លារអាមេរិក/ឆ្នាំ) |
|---|---|---|---|
| ព្រៃស្រោង | 0,00 | 0,00 | 0,00 |
| ព្រៃពាក់កណ្តាលស្រោង | ៣៩.១៥៤,៥០ | ១៤៣.៥៧៩,៥៥ | ១៩៥.៧៧២,៥០ |
| ព្រៃល្បោះ | ៩២១.៩៦០,00 | ៣.៣៨០.៨២៧,៣២ | ៤.៦០៩.៨00,00 |
| ***សរុប*** | ៩៦១.១១៤,៥០ | ៣.៥២៤.៤០៦,៨៧ | ៤.៨០៥.៥៧៣ |

សំគាល់:
-តម្លៃកាបូនក្នុងទីផ្សារស្ម័គ្រចិត្តបច្ចុប្បន្ន ៥USD/ហិកតា
-ព្រៃស្រោងបាត់បង់ចំនួន 0,00ហិកតា
-ព្រៃពាក់កណ្តាល់ស្រោង បាត់បង់ចំនួន ២៣១,00ហិកតា
-ព្រៃល្បោះ បាត់បង់ចំនួន ៧.៦៨៣,00ហិកតា

### ៩.៣.១.២ សេវាកម្មអភិរក្សទឹក និង ដី

ការបាត់បង់គម្របព្រៃ ធ្វើឲ្យប៉ះពាល់ដល់ឱនភាពដី ដោយបង្កឲ្យមានការហូរច្រោះតាមរយៈសំណឹកដីដោយទឹកភ្លៀង និងខ្យល់ ការប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ជាដើម។ បន្ថែមលើសពីនេះទៅទៀត បរិមាណ និងល្បឿនទឹកហូរនៅលើផ្ទៃដីមានកម្រិតខុសៗគ្នាអាស្រ័យលើបរិមាណទឹកភ្លៀង និងកន្លែងដែលទឹកភ្លៀងធ្លាក់មកលើផ្ទៃដី។ ជាក់ស្តែងព្រៃធម្មជាតិអាចស្ទាក់ទឹកទុកក្នុងបរិមាណយ៉ាងច្រើន និងអាចកាត់បន្ថយល្បឿនទឹកហូរ ធ្វើឲ្យបរិមាណទឹកជាយ៉ាងច្រើនជ្រាបចូលទៅក្នុងដី។ នៅតាមកន្លែងដែលអស់ព្រៃ ឬចម្ការធំៗ ទឹកហូរនៅលើផ្ទៃដីមានល្បឿនលឿនខ្លាំង ដូច្នេះមានទឹកតិចតួចប៉ុណ្ណោះដែលអាចជ្រាបចូលទៅក្នុងដី ដែលទាំងនេះជាកត្តាដែលធ្វើឲ្យប៉ះពាល់ទឹកក្រោមដី។ ដូចគ្នានេះដែរ នៅពេលដែលមានភ្លៀងខ្លាំងវាអាចបង្កជាទឹកជំនន់ព្រោះតែល្បឿនទឹកហូរខ្លាំងពេក ខណៈពេលដែលមិនមានគម្របព្រៃទប់។ នៅតំបន់វៀតណាមកណ្តាល ដែលជាតំបន់មានលក្ខណៈស្រដៀងគ្នាជាមួយនឹងតំបន់ខ្ពង់រាបប្រទេសកម្ពុជា ត្រូវបានគេដឹងថា សំណឹកដីជាបញ្ហាចម្បងរបស់កសិករនៅក្នុងប្រទេសទាំងពីរនេះ ពិសេសជនជាតិដើមភាគតិចដែលរស់នៅពឹងផ្អែកលើការធ្វើកសិកម្មពនេចរ ( The, 2001 )។

ការកែតម្រូវទៅតាមភាពខុសគ្នានៃប្រាក់ចំណូល ត្រូវបានធ្វើឡើងដោយហេតុថា តម្រូវការទំនិញ និងសេវាកម្មស្ទើរតែទាំងអស់ (រួមទាំងសេវាកម្មនៃមុខងារប្រព័ន្ធអេកូឡូស៊ី) មានការប្រែប្រួលទៅតាមប្រាក់ចំណូល។ ជាទូទៅកាលណាប្រាក់ចំណូលកើនឡើង តម្រូវការក៏មានការកើនឡើងដែរ ហើយចំនួនទឹកប្រាក់ដែលស្ម័គ្រចិត្តចំណាយ (Willingness to pay – WTP) ដើម្បីទទួលបាន ឬជៀសវាងការបាត់បង់សេវាកម្មនោះ ក៏មានការកើនឡើងផងដែរ។ ដើម្បីប៉ាន់ស្មានតម្លៃនៃផល និងអនុផលព្រៃឈើដែលបានបាត់បង់ដោយសារគម្រោង យើងពឹងផ្អែកលើលទ្ធផលនៃការសិក្សារបស់ Hansen & Neth ( ឆ្នាំ២០០៦ ) គោលការណ៍ណែនាំរបស់ UNEP (Brander 2013) នឹងត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណពីតម្លៃនៃផល និងអនុផលព្រៃឈើទាំងនេះ។ នោះមានន័យថាតម្លៃដែលបានបង់នៅក្នុងឆ្នាំ ២០០៦ ត្រូវបម្លែងជាតម្លៃដែលនឹងត្រូវបង់ចំពោះសេវាកម្មនៅក្នុងឆ្នាំ ២០១៥ ដោយគិតនៅលើ

តម្លៃនៃការប្រែប្រួលនៃចំណូលតាមឆ្នាំ (GDP Deflector Index នៅក្នុងការសិក្សាមានត្រឹមឆ្នាំ២០១៤ ប៉ុណ្ណោះដូចនេះយើងអាធ្វើការសន្មត់បានថា GDP Deflector Index មានតម្លៃស្មើនឹង GDP Deflector Index បំពោះឆ្នាំ ២០១៥នេះ)[1]។

ជាលទ្ធផលបានបង្ហាញថា នៅក្នុងមួយឆ្នាំ តម្លៃនៃការអភិរក្សទឹក និងដីនៃប្រភេទព្រៃទាំង ២ប្រភេទនេះត្រូវបានគេប៉ាន់ប្រមាណថាមានប្រមាណជា *៤៦២.៧៤៣* ដុល្លារអាមេរិក/ឆ្នាំ តែដោយសារគម្រោងមានថេរវេលា ៥០ឆ្នាំ ដូចនេះតម្លៃសរុបនៃសេវាកម្មអភិរក្សនេះកើនឡើងដល់ *២៣.១៣៧.១៥០* ដុល្លារអាមេរិក តម្លៃនេះត្រូវបានគិត ក្នុងករណីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។

តារាង ៩.៥ ៖ ការប៉ាន់ប្រមាណតម្លៃសេដ្ឋកិច្ចពីវិស័យព្រៃឈើលើផ្នែកសេវាកម្មអភិរក្សទឹក និងដី

| ប្រភេទព្រៃ | តម្លៃសេវាកម្ម(ដុល្លារ/ឆ្នាំ) |
|---|---|
| ព្រៃស្រោង | ០,០០ |
| ព្រៃពាក់កណ្ដាល់ស្រោង | ២៣.០៨៨,៨៥ |
| ព្រៃល្បោះ | ៤៣៩.៦៥៤,០៨ |
| *សរុប* | *៤៦២.៧៤៣* |

៩.៣.១.៣ តម្លៃនៃផល និងអនុផលព្រៃឈើ

ផ្អែកតាមការស្រាវជ្រាវ យើងបានរកឃើញតែការសិក្សារបស់ Hansen & Top (ឆ្នាំ២០០៦) មួយគត់ដែលបានធ្វើការគណនាតម្លៃនៃផលឈើនៅក្នុងប្រទេសកម្ពុជា តាមរយៈលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃឈើដោយផ្ទាល់ និងបានគិតពីការចំណាយលើការប្រមូលផលឈើ។ លទ្ធផលនៃការសិក្សានេះជាផលចំណេញសេដ្ឋកិច្ចសុទ្ធដែលទទួលបានពីការគ្រប់គ្រងព្រៃឈើ និងការដកហូតផលឈើប្រកបដោយនិរន្តរន៍ភាព។ របាយការណ៍របស់ Cambodia REDD+ Taskforce Secretariat (២០១៤) បានបង្ហាញថាមានការសិក្សាអំពីតម្លៃនៃផលឈើចំនួន ០៦ ផ្សេងទៀត នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែតាមការពិនិត្យការសិក្សាទាំងនោះ មិនផ្អែកលើលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃឈើដោយផ្ទាល់ និងការគិតគូរពីការចំណាយលើការប្រមូលផលឈើឲ្យបានគ្រប់ជ្រុងជ្រោយ ដូចជាការសិក្សារបស់ Hansen & Top (ឆ្នាំ២០០៦) នោះទេ (Kasper K. Hansen. & Top, 2006)។ ការសិក្សារបស់ Hansen & Top (ឆ្នាំ២០០៦) អំពីតម្លៃនៃអនុផលព្រៃឈើ ក៏ជាការសិក្សាមួយដែលស្រដៀងបំផុតទៅនឹងការសិក្សាក្នុងពេលបច្ចុប្បន្ន (ក្នុងបរិបទនៃការប្រែក្លាយដីព្រៃទៅជាដីកសិកម្មក្នុងប្រទេសកម្ពុជា)។ ដើម្បីប៉ាន់ស្មានតម្លៃនៃផល និងអនុផលព្រៃឈើដែលបានបាត់បង់ដោយសារគម្រោង យើងពឹងផ្អែកលើលទ្ធផលនៃការសិក្សារបស់ Hansen & Neth (ឆ្នាំ២០០៦)។ គោលការណ៍ណែនាំរបស់ UNEP (Brander, 2013) ត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណពីតម្លៃទាំងនេះ ដោយធ្វើការបំលែងពីតម្លៃនៃការបង់សេវាកម្មនៅក្នុងឆ្នាំ ២០០៦ មកជាតម្លៃដែលត្រូវបង់ពន្ធនៅក្នុងឆ្នាំ២០១៥ វិញ។

ជាលទ្ធផល តម្លៃនៃផលព្រៃឈើ ដែលប៉ាន់ប្រមាណបាត់បង់ដោយសារគម្រោងមានចំនួន ៦.៣៩៤,៥៨ ដុល្លារអាមេរិក/ឆ្នាំ ខណៈដែលអនុផលព្រៃឈើមានចំនួន ៣.៩៧៥,០១ ដុល្លារអាមេរិក/ឆ្នាំ ក្នុងករណីព្រៃពាក់កណ្ដាលស្រោង។ ចំណែកឯព្រៃល្បោះវិញចំនួនទឹកប្រាក់ដែលប៉ាន់ប្រមាណបាត់បង់ដោយសារគម្រោងកើនឡើងដល់ ២១២.៦៨១,៩៧ ដុល្លារអាមេរិក/ឆ្នាំចំពោះតម្លៃនៃអនុផលព្រៃឈើ។ សរុបតម្លៃនៃផលប្រយោជន៍ពីព្រៃឈើ

[1] ដោយសារតែ GDP Deflector Index ដែលមាននៅក្នុងទិន្នន័យរបស់ធនាគារពិភពលោក (World Bank) មានត្រឹមឆ្នាំ ២០១៤ ដូចនេះទើបសន្មតយក Deflector Index មានតម្លៃស្មើនិងឆ្នាំ ២០១៥តែម្តង។

ដែលបាត់បង់ដោយសារតែគម្រោងមានរហូតដល់ ***២២៣.០៥២*** ដុល្លារអាមេរិក/ឆ្នាំ នេះបើគិតក្នុងលក្ខខណ្ឌការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ ដោយសារតែគម្រោងមានរយៈពេល ៥០ឆ្នាំ ដូចនេះតម្លៃជារួមដែលបាត់បង់ដោយសារគម្រោង ពីវិស័យព្រៃឈើមានចំនួន ***១១.១៥២.៦០០***ដុល្លារអាមេរិក។

តារាង ៩.៦ ៖ ការប៉ាន់ប្រមាណតម្លៃសេដ្ឋកិច្ចពីវិស័យព្រៃឈើលើផ្នែកផល និងអនុផលព្រៃឈើ

| ប្រភេទ | តម្លៃសរុប(ដុល្លា/ឆ្នាំ) | | |
|---|---|---|---|
| | ផល | អនុផល | សរុប |
| ព្រៃស្រោង | ០,០០ | ០,០០ | ០,០០ |
| ព្រៃពាក់កណ្តាលស្រោង | ៦.៣៩៤,៥៨ | ៣.៩៧៥,០១ | ១០.៣៦៩,៥៨ |
| ព្រៃល្បោះ | ០,០០ | ២១២.៦៨១,៩៧ | ២១២.៦៨១,៩៧ |
| ***សរុប*** | | | ***២២៣.០៥២*** |

## ៩.៤. តម្លៃសង្គម

### ៩.៤.១ តម្លៃអវិជ្ជមាននៃគម្រោងលើសង្គម

#### ៩.៤.១.១ មុខរបរ និងប្រាក់ចំណូល

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានការពឹងផ្អែកលើវិស័យកសិកម្ម ហើយភាគច្រើននៃប្រជាពលរដ្ឋគឺអាស្រ័យនៅលើដី និងធនធានធម្មជាតិដូចជាព្រៃឈើ និងផលផលដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ ជាពិសេសនៅតាមជនបទ ភាគច្រើនពួកគេភ្ជាប់ធនធានទាំងអស់នោះទៅជាវប្បធម៌ និងអបិយជំនឿ (OHCHR, 2007) ។ ព្រៃឈើនេះក៏ជាប្រភពដ៏សំខាន់នៃប្រាក់ចំណូលសម្រាប់កសិករកម្ពុជា។ ជាការពិតណាស់ ពួកគេអាចចូលទៅក្នុងព្រៃ និងប្រមូលជ័រ ផលិតផលឱសថ ផ្សិត .ល. ដើម្បីយកទៅលក់នៅក្នុងទីផ្សារ។ ដូច្នេះព្រៃឈើអាចធ្វើឲ្យពួកគេបង្កើននូវចំណូលបន្ថែមទៀត ដើម្បីបង្កើនការស្តង់ដារនៃការរស់របស់ពួកគេ លើសពីការចិញ្ចឹមជីវិតដែលមានភាពសាមញ្ញ (LICADHO, 2005)។ ជាអកុសល ការដណ្តើមយកដីនិងការកាប់ឈើដោយសារការសម្បទាន វាបានបំផ្លាញប្រព័ន្ធអេកូឡូស៊ី រុក្ខជាតិនិងភាពសម្បូរបែបនៃសត្វ ដែលទាំងនេះជាប្រភពដ៏សំខាន់នៃប្រាក់ចំណូលសម្រាប់កសិករ (LICADHO, 2005)។ ដូច្នេះហើយ ទើបមានប្រជាជនមួយចំនួន (ពិសេសប្រជាជននៅក្នុងតំបន់គម្រោង) បានបាត់បង់មុខរបររកអនុផលព្រៃឈើ ដែលជាមុខរបរបន្ទាប់បន្សំក្រៅពីការធ្វើស្រែចម្ការរបស់ពួកគេ។ មុខរបរទាំងនេះ ពុំអាចធ្វើការញែកដាច់ពីគ្នាបានទេ ពីព្រោះវាអាស្រ័យលើរដូវកាលនៃការប្រមូលផល និងវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងប្រតិទិនរដូវកាលនៃការប្រមូលអនុផលព្រៃឈើ។

### ៩.៤.២ តម្លៃវិជ្ជមាននៃគម្រោងលើសង្គម

#### ៩.៤.២.១ មុខរបរថ្មី និងប្រាក់ចំណូល

សម្បទានដីសេដ្ឋកិច្ចត្រូវបានគេកំណត់ថា វាជាយន្តការមួយក្នុងការផ្តល់ដីឯកជនរបស់រដ្ឋ ឲ្យទៅក្រុមហ៊ុនឯកជនសម្រាប់ធ្វើកសិកម្ម និងការធ្វើអាជីវកម្មផ្នែកឧស្សាហកម្មបែបកសិកម្ម។ គោលបំណងដែលពួកគេអាចនឹងទទួលបានរួមបញ្ចូលមានទាំងការវិនិយោគនៅក្នុងវិស័យកសិកម្ម និងពាំនាំមកនូវឱកាសការងារថ្មីៗសម្រាប់ប្រជាជននៅជនបទសម្រាប់ចិញ្ចឹមជីវិត និងផ្តល់ប្រាក់ចំណូលចូលរដ្ឋ (OHCHR, 2007)។ នៅក្នុងគម្រោងវិនិយោគនេះ ក្រុមហ៊ុននឹងប្រើប្រាស់កម្លាំងពលកម្មដែលមានក្នុងស្រុក ដើម្បីចូលរួមកាត់បន្ថយភាពគ្មានការងារធ្វើរបស់បុគ្គលិក

ឬអ្នកបច្ចេកទេសកម្ពុជា ដែលបានបណ្តុះបណ្តាលរួចពីគ្រឹះស្ថានបច្ចេកទេសនានា និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅក្នុងតំបន់ ដែលស្របតាមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។

ចំនួននៃបុគ្គលិក-កម្មករ អ្នកបច្ចេកទេស និងអ្នកគ្រប់គ្រងដែលត្រូវការនៅក្នុងការបំពេញការងារមានប្រមាណជា ៣១៩នាក់នៅក្នុងឆ្នាំទី១ និងមានឡើងរហូតដល់ ២.០៥៨នាក់ នៅក្នុងឆ្នាំទី៥។ នៅចន្លោះឆ្នាំទី៦ដល់ឆ្នាំទី១០ តម្រូវការកម្លាំងពលកម្មនឹងកើនឡើងពី ២.៣៦៧នាក់ ដល់ ២.៦៧៤នាក់សម្រាប់អាជីវកម្មនេះចំណែកឯឆ្នាំទី១៥ កម្លាំងពលកម្មនឹងធ្លាក់ចុះមកត្រឹម ២.០៥២នាក់វិញ។

ចំនួននៃបុគ្គលិក កម្មករ អ្នកបច្ចេកទេស និងអ្នកគ្រប់គ្រងដែលត្រូវការនៅក្នុងការបំពេញការងារមានប្រមាណជា ៣១៩នាក់នៅក្នុងឆ្នាំទី០១ និងមានឡើងរហូតដល់ ២.០៦៤នាក់ នៅក្នុងឆ្នាំទី០៥។ នៅចន្លោះឆ្នាំទី០៨ ដល់ ឆ្នាំទី១០ តម្រូវការកម្លាំងពលកម្មនឹងត្រូវការប្រមាណជា ១.៦៥៣នាក់។

ថវិកាដែលត្រូវចំណាយសម្រាប់កម្លាំងពលកម្មក្នុងស្រុក ក្រុមហ៊ុនចំណាយប្រមាណជា២០៩.០០០លានដុល្លារនៅក្នុងឆ្នាំទី០១ នឹងកើនឡើងដល់១.១៤៦.៦០០លានដុល្លារអាមេរិកនៅក្នុងឆ្នាំទី០៥ ។ ចំណែកការចំណាយក្នុងឆ្នាំទី១០មានប្រមាណជា ១.១៤៧.៨០០លានដុល្លារ។

ប្រាក់បៀវត្សរ៍គោលសម្រាប់បុគ្គលិកដែលបម្រើការនៅក្នុងគម្រោងវិនិយោគត្រូវបានកំណត់ដូចខាងក្រោមនេះ៖

- វិស្វករ ទទួលបាន ៥០០-៧០០ដុល្លារអាមេរិកក្នុងមួយខែ
- អ្នកគ្រប់គ្រងក្រុម ទទួលបាន ២៥០-៣០០ដុល្លារអាមេរិកក្នុងមួយខែ
- អ្នកចាត់ការ-គ្រប់គ្រងទូទៅ ទទួលបាន ៧០០-៩៥០ដុល្លារអាមេរិកក្នុងមួយខែ
- អ្នកគ្រប់គ្រងផ្នែករដ្ឋបាល ទទួលបាន ២៥០-៣៥០ដុល្លារអាមេរិកក្នុងមួយខែ
- កម្មករជំនាញ(អចិន្ត្រៃយ៍) ទទួលបាន ៨០-១១០ដុល្លារអាមេរិកក្នុងមួយខែ
- កម្មករបណ្តោះ(តាមរដូវកាល) ទទួលបាន ៥៥-៩០ដុល្លារអាមេរិកក្នុងមួយខែ

ការធានារ៉ាប់រងផ្នែកសង្គមត្រូវបានគិតប្រមាណជា ៧%នៃទឹកប្រាក់ដែលចំណាយសម្រាប់កម្លាំងពលកម្មសរុប។ នៅឆ្នាំទី១ ត្រូវបានចំណាយប្រមាណជា១៤.៦៣០ដុល្លាអាមេរិក សម្រាប់ការធានារ៉ាប់រងផ្នែកនេះ នៅឆ្នាំទី០៥ចំណាយប្រមាណជា ៧១.៨៤២ដុល្លារអាមេរិកចំណែកឯឆ្នាំទី១០ កើនឡើងដល់ ៧៥.០១៣៨ដុល្លារអាមេរិក/ឆ្នាំ។

Draft

ក្រាហ្វិក ៩.១ ៖ តារាងសង្ខេបតម្រូវការកម្លាំងពលកម្ម និងការចំណាយ




៩.៤.២.២ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

នៅក្នុងគម្រោងនៃការវិនិយោគផ្លូវចំនួន ០៥ ប្រភេទនឹងត្រូវបានធ្វើការសាងសង់ដើម្បីជាការសម្រួលដល់ដំណើរការនៃការងារ និងសម្រាប់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរ។ ផ្លូវនេះ នឹងត្រូវបានស្ថាបនាថ្មីទាំងអស់ដោយមិនរាប់បញ្ចូលផ្លូវចាស់ដែលមានស្រាប់នៅក្នុងតំបន់ឡើយ។ ចំពោះផ្លូវដែលមានស្រាប់(ផ្លូវចាស់) ក្រុមហ៊ុន និងធ្វើការសហការជាមួយអាជ្ញាធរ ក៏ដូចជាប្រជាជនដើម្បីធ្វើការជួសជុសផ្លូវទាំងនោះឲ្យមានភាពប្រសើរឡើងវិញក្នុងគោលបំណងដើម្បីប្រើប្រាស់ជាសាធារណៈ។

ផ្លូវដែលគ្រោងនឹងធ្វើការស្ថាបនានោះមានដូចជា:

- ផ្លូវព្រំ ជុំវិញតំបន់គម្រោងចំនួន ១ខ្សែប្រវែង ៦០គ.ម ជាមួយទទឹង ១២ម
- ផ្លូវមេ ក្នុងតំបន់គម្រោងចំនួន ១ខ្សែប្រវែង៧គ.ម ជាទទឹង ១០ម
- ផ្លូវមេចែកអនុតំបន់ ក្នុងតំបន់គម្រោងមានចំនួន ០៤ខ្សែ ប្រវែង ១៤គ.ម ជាមួយទទឹង៨ម
- ផ្លូវមេក្នុងអនុតំបន់ មានចំនួន ១៥ខ្សែប្រវែង៩២គ.ម ជាមួយទឹង៦ម
- ផ្លូវឡូតិ៍ មានចំនួន ៣៥ខ្សែប្រវែង១៥៩គ.ម ជាមួយទទឹង ៤ម

នៅក្នុងដំណើរការនៃគម្រោងផ្នែកហេដ្ឋារចនាសម្ព័ន្ធគ្រោង នឹងចំណាយអស់ទឹកប្រាក់ប្រមាណជា ១.៣៣០.០០០ដុល្លារអាមេរិក ដែលទឹកប្រាក់នេះមិនបានរាប់បញ្ចូលលើការសាងសង់សំណង់រោងចក្រឡើយ គឺជាការចំណាយសុទ្ធលើសំណង់ ផ្លូវ និងអគារតែប៉ុណ្ណោះ។ ការគិតគូរលើទឹកប្រាក់ចំណាយខាងលើនេះ នៅមិនទាន់បានរាប់ញ្ចូលទាំងតម្លៃនៃការជួសជុសផ្លូវចាស់ដែលមាននៅក្នុងតំបន់ស្រាប់នៅឡើយនោះទេ ពោលគឺជាតម្លៃនៃការវិនិយោគក្នុងតំបន់គម្រោងតែបុណ្ណោះ។

៩.៤.២.៣ ការបង់ពន្ធ-ប៉ាតង់

អនុលោមតាមកិច្ចសន្យាដែលធ្វើឡើងនៅក្នុងថ្ងៃទី ០៨ ខែវិច្ឆិការ ឆ្នាំ ២០១១របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានកាគីពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងក្រុមហ៊ុនស្តីពី ការវិនិយោគដាំដំណាំ

Draft

អាកាស្យា និងអំពៅបានធ្វើការបញ្ជាក់ក្នុងប្រកាស ០៤ អំពីថេរវេលានៃគម្រោងថា កិច្ចសន្យានៃការជួលដីសម្រាប់ធ្វើការដាំដុះនេះមានរយៈពេល ៥០ឆ្នាំ។

នីតិវិធីនៃការបង់ពន្ធរបស់ក្រុមហ៊ុនបានបញ្ជាក់នៅផ្នែកទី០២ នៃប្រកាស ០៩ស្តីពីកិច្ចសន្យានៃថ្លៃបង់ពន្ធដូចខាងក្រោម៖

- សម្រាប់ដំណាំអាកាស្យា(ដំណាំយូរឆ្នាំ និងអចិន្ត្រៃយ៍) ត្រូវបានអនុគ្រោះតម្លៃសម្បទានក្នុងរយៈពេល ៥ឆ្នាំដំបូង បន្ទាប់ពីចុះហត្ថលេខាលើកិច្ចសន្យានេះ។ នៅឆ្នាំបន្ទាប់និងចាប់ផ្តើមធ្វើការបង់ពន្ធក្នុងមួយឆ្នាំ ០៥ ដុល្លាអាមេរិកក្នុងមួយហិកតា។ បន្ទាប់មកតម្លៃសម្បទាននេះនិងកើនឡើង ៥% ជារៀងរាល់ឆ្នាំ។ ក្នុងករណីដែលចាំបាច់តម្លៃនេះនិងត្រូវធ្វើការត្រួតពិនិត្យនៅរាល់រយៈពេល ០៥ឆ្នាំម្តង។
- សម្រាប់ដំណាំអំពៅ(ដំណាំរដូវ និងដំណាំប្រចាំឆ្នាំ) ក្រុមហ៊ុនត្រូវធ្វើការបង់ថ្លៃសម្បទានក្នុងមួយហិកតាចំនួន ៥ដុល្លាអាមេរិក/ឆ្នាំ លើផ្ទៃដីដែលបានដាំដុះធ្វើអាជីវកម្មរួច។ បន្ទាប់មកតម្លៃសម្បទាននេះនិងកើនឡើង ៥%ជារៀងរាល់ឆ្នាំ។ ក្នុងករណីដែលចាំបាច់តម្លៃនេះនិងត្រូវធ្វើការត្រួតពិនិត្យនៅរាល់រយៈពេល ០៥ឆ្នាំម្តង។

តាមរយៈកិច្ចសន្យានេះ ការអនុវត្តពន្ធត្រូវបានចាប់ផ្តើមគិតនៅក្នុងឆ្នាំទី០២នៃដំនាំអំពៅ និងឆ្នាំទី០៦ នៃដំណាំអាកាស្យា(ដោយសារតែមានការលើកលែងពន្ធ ចំពោះដំណាំអាកាស្យាក្នុងរយៈពេល ០៥ឆ្នាំដំបូង អនុលោមតាមកិច្ចសន្យា)។ ដូចនេះមានន័យថា ចាប់ពីឆ្នាំទី០១ ដល់ឆ្នាំទី៥នៃការងារដាំដុះពន្ធត្រូវបានគិតតែនៅលើដំណាំអំពៅមួយមុខគត់ ហូតដល់ឆ្នាំទី០៦ ទើបគិតទាំងពន្ធនៃដំណាំអាកាស្យា។ ការងារដាំដុះ គ្រោងនឹងបញ្ចប់នៅក្នុងឆ្នាំទី ០៧ នោះតម្លៃនៃពន្ធ នឹងត្រូវបានគិតពេញលេញ ជាមួយកំណើន ៥% ក្នុងមួយឆ្នាំជារៀងរាល់ឆ្នាំដូចមានចែងក្នុងកិច្ចសន្យា ហូតដល់ឆ្នាំបញ្ចប់កិច្ចសន្យាសម្បទាន។ ចំពោះរយៈពេល ០៦ឆ្នាំដំបូង ដែលជាដំណាក់កាលនៃការការងារដាំដុះថ្លៃពន្ធនឹងត្រូវបានគិតទៅតាមកំណើននៃផ្ទៃដីដាំដុះជាមួយនិងកំណើន៥% នៃតំលៃបង់ពន្ធនៃឆ្នាំនោះតែប៉ុណ្ណោះ។

## ៩.៥ ការប៉ះប៉ូវតម្លៃអវិជ្ជមានផ្នែកសេដ្ឋកិច្ច-សង្គម

ដើម្បីជាការប៉ះប៉ូវដល់ការប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថាន ដែលផ្តោតជាសំខាន់លើឱកាសនៃការទទួលបាននូវផលប្រយោជន៍ពីវិស័យព្រៃឈើនៅក្នុងតំបន់ ក៏ដូចជាផ្នែកមួយនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍មូលដ្ឋានគម្រោងមានកញ្ចប់ថវិកាប្រមាណ ៩០.០០០ដុល្លាអាមេរិកនៅក្នុងមួយឆ្នាំ នៅក្នុងការអនុវត្តន៍សកម្មភាពនានាក្នុងគោលបំណង់លើកស្ទួយដល់ផ្នែកជីវភាពប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឲ្យមានភាពប្រសើរឡើង។ នៅក្នុងរយៈពេលសរុប ៥០ឆ្នាំ គម្រោងនឹងអាចចំណាយថវិកានេះប្រមាណជា $៩៨២,៣៣៣.៣០ ដុល្លាអាមេរិក (គិតក្នុងអត្រាបញ្ចុះតម្លៃ ១០%) ដល់សហគមន៍ ដើម្បីជាផ្នែកមួយនៃការប៉ះប៉ូវវិញនូវការខាតបង់ដែលអាចកើតពីពីគម្រោង។

## ៩.៦ សន្និដ្ឋាន

តាមរយៈការវិភាគបានបង្ហាញថា គម្រោងនឹងប្រើប្រាស់ការចំណាយរបស់ខ្លួនលើការវិនិយោគនេះប្រមាណជា ២៦.៤០២.២៣០ដុល្លាអាមេរិក ដើម្បីសម្រេចបានលើសកម្មភាពសំខាន់ៗរបស់ខ្លួន។ ចំណែកសម្រាប់សន្ទស្សន៍សេដ្ឋកិច្ចសំខាន់ៗមានដូចជា៖ អត្រាចំណូលផ្ទៃក្នុង (IRR) ចំនួន ១៦,៧០% រយៈពេលប្រមូលថ្លៃដើម (Payback Period) មានរយៈពេល ១២ឆ្នាំ ខណៈដែលសន្ទស្សន៍ផលចំណេញ (Profitability Index) សម្រាប់រយៈ

ពេល ២០ឆ្នាំដំបូងមានចំនួន ១,៤៩។ ដោយឡែក តាមរយៈការវិភាគតម្លៃ ឱកាសនៃការបាត់បង់ផលចំណេញពីវិស័យបរិស្ថានធម្មជាតិបានបង្ហាញថា តម្លៃឱកាសពីការប៉ាន់ប្រមាណនៃការបាត់បង់សម្រាប់វិស័យស្តុក និងស្រូបកាបូនមានប្រមាណជា ៤.៥៩០.០០០ដុល្លាអាមេរិក/ឆ្នាំ ការបាត់បង់តម្លៃឱកាសនៃសេវាកម្មអភិរក្សទឹក និងដីមានប្រមាណជា ២៣.១៣៧.១៥០ដុល្លាអាមេរិក/ឆ្នាំ ខណៈដែលតម្លៃឱកាសពីការបាត់បង់ផលចំណេញពី ផល-អនុផលព្រៃឈើមានប្រមាណជា ១១.១៥២.៦០០ដុល្លាអាមេរិក/ឆ្នាំ។

នៅក្នុងរយៈពេល ៥០ឆ្នាំ របស់គម្រោងវិនិយោគៈ

- តម្លៃបច្ចុប្បន្នសុទ្ធរបស់គម្រោងមានប្រមាណ ២៥.៧៦៣.៤៩៥ដុល្លារអាមេរិក ៤.០៤០.៧១៧ ដុល្លារអាមេរិក និង (-) ៣.២៧៨.៦០៤ដុល្លាអាមេរិក
- ផលចំណេញសម្រាប់កម្ពុជា ពីការបង់ពន្ធលើប៉ាតង់ ៥៤.២១០.៩១៥ ដុល្លាអាមេរិក
- ផលចំណេញសម្រាប់កម្ពុជាពីការងារដែលផ្តល់ដោយគម្រោង ៥៥.៤០៣.៤០០ដុល្លាអាមេរិក

ប៉ុន្តែទោះជា គម្រោងផ្តល់ចំណេញដល់កម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់ក្តី តែវាបានបង្កបញ្ហាសម្រាប់បរិស្ថានផងដែរ។ គិតនៅក្នុងរយៈពេល ៥០ឆ្នាំរបស់គម្រោងផលខាតបង់ប្រមាណជា ២៧៤.៥៦៨.៤០០ដុល្លារអាមេរិក ប៉ុន្តែតម្លៃនេះគ្រាន់ជាតម្លៃឱកាសប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តីតម្លៃនៃការខាតបង់នេះមិនមែនជាតម្លៃនៃការខាតបង់សេដ្ឋកិច្ចសុទ្ធសាធនោះទេ តម្លៃដែលបានប៉ាន់ស្មានគឺជាតម្លៃខូចខាតដោយសារបាត់បង់ឱកាសទទួលបានផលិតផល/សេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ក្នុងករណីព្រៃឈើទាំងនោះត្រូវបានគ្រប់គ្រងដោយនិរន្តភាព ដើម្បីទទួលបានផល អនុផលព្រៃឈើ សេវាកម្មអភិរក្សទឹក សេវាកម្មអភិរក្សដី និងសេវាកម្មស្តុកកាបូន។ ដូចដែលបានបង្ហាញនៅក្នុងជំពូក៥ (ផ្នែកធនធានជីវសាស្ត្រ) ព្រៃឈើក្នុងតំបន់គម្រោងមុន និងក្នុងពេលដំណើរការឈូសឆាយដាំដុះរបស់គម្រោងបានទទួលរងនូវការពនេចម្ការពីសំណាក់ប្រជាជន។ ដូច្នេះ ដើម្បីគ្រប់គ្រងព្រៃឈើទាំងនោះឲ្យមាននិរន្តភាព ទាមទារនូវថវិការជាច្រើន ដែលយើងមិនអាចប៉ាន់ស្មានបានតែយើងក៏អាចសន្និដ្ឋានបានថា ផលិតផល/សេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើដែលបាត់បង់មានតម្លៃទាបជាងតម្លៃដែលប៉ាន់ស្មានខាងលើ។

ដោយឡែកវត្តមាននៃគម្រោងនឹងចូលរួមចំណែកបាននៅ ផលចំណេញដល់ប្រជាជនកម្ពុជានូវ ការបំពេញនូវតម្រូវការការងារនៅក្នុងតំបន់មូលដ្ឋានដែលអាចឈានដល់ ការកាត់បន្ថយបាននូវអត្រានៃការធ្វើចំណាកស្រុកដើម្បី ការងារនៅក្នុងតំបន់មកត្រឹមកម្រិតអប្បបរមា ឬគ្មានការធ្វើចំណាក់ស្រុកតែម្តងដោយសារការងារនៅក្នុងតំបន់គម្រោង។ លើសពីនេះ មុខរបរបន្ទាប់បន្សំនានានៅក្នុងនឹងក្បែរតំបន់គម្រោងនឹងត្រូវបានរីកដុះដាល ដែលជាផ្នែកមួយនៃការជួយជំរុញផ្នែកសេដ្ឋកិច្ចនៃតំបន់ ដែលជាអ្វីដែលរដ្ឋាភិបាលកម្ពុជាចង់បាន ដើម្បីធ្វើឲ្យចន្តសេដ្ឋកិច្ចនៅផ្នែកជនបទប្រទេសមានការដើរជឿនលឿនទៅថ្ងៃខាងមុខ។ ក្រៅពីការផ្តល់ជាមុខរបរដល់ប្រជាជននៅក្នុងតំបន់មូលដ្ឋាន គម្រោងក៏នឹងរួមចំណែកដល់ វិស័យសេដ្ឋកិច្ចនៃប្រទេសកម្ពុជាផងដែរតាមរយៈការបង់ពន្ធជូនរដ្ឋ។

ដូច្នេះគម្រោងវិនិយោគនេះ ពិតជាផ្តល់ផលចំណេញជាសាច់ប្រាក់សុទ្ធសម្រាប់សេដ្ឋកិច្ចជាតិ ពិសេសបានចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការផ្តល់កាងារធ្វើជូនដល់ប្រជាជននៅក្នុងមូលដ្ឋាន និងរួមចំណែកនៅក្នុងការបង្កើនសេដ្ឋកិច្ចប្រទេសតាមរយៈការបង់ពន្ធជូនប្រទេសជាតិទាំងមូលផងដែរ។

Draft